ADB

# ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់
# ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ីប៉ាស៊ីហ្វិក៖
# ការអភិវឌ្ឍជើងឯកផ្នែកនីតិបរិស្ថាន
# កម្មវិធីការបណ្តុះបណ្តាលគ្រូបង្គោល
# ថ្ងៃទី ២៧ ខែ វិច្ឆិកា - ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧
# ខេត្តសៀមរាប ប្រទេសកម្ពុជា

IUCN ACADEMY OF ENVIRONMENTAL LAW

## វគ្គទី ១៥ និង ១៦៖ ទស្សនកិច្ចសិក្សា

## មជ្ឈមណ្ឌលអង្គរសម្រាប់អភិរក្សជីវៈចម្រុះ

### សាវតា[1]

មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវសាស្រ្តចម្រុះ (ACCB) ត្រូវបានបង្កើតឡើងរួមគ្នាជាមួយ Münster Zoo និង Zoological Society for the Conservation of Species and Populations (ZGAP) ក្នុងឆ្នាំ ២០០៣។ ACCB គឺជាកម្មវិធីស្តានីតីសម្បទាសត្វព្រៃមួយក្នុងចំណោមកម្មវិធីស្តានីតិសម្បទាសត្វព្រៃចំនួនពីរក្នុងប្រទេសកម្ពុជា។ ACCB មានទីតាំងលើផ្ទៃដីទំហំ ២៥ ហិចតាក្នុងទីតាំងជនបទមួយ ចម្ងាយ ៤០ គីឡូម៉ែត្រនៅខាងក្រៅក្រុងសៀមរាប នៅភាគពាយព្យប្រទេសកម្ពុជា។ ផ្ទៃដីរបស់ ACCB តាំងនៅជើងភ្នំក្បាលស្ពាន ក្នុងឧទ្យានជាតិភ្នំគូលែន។ តំបន់នេះមានអាកាសធាតុត្រូពិច ស្ថិតក្នុងព្រៃពាក់កណ្តាលស្រោងដោយមានដើមឈើជ័រទឹក dipterocarp ដុះជាច្រើន ហើយដើរតួនាទីជាទីជម្រកសម្រាប់ពូជសត្វផ្សេងៗជាច្រើនសន្ធឹកសន្ធាប់។

---

[1] ព័ត៌មានសាវតាខាងក្រោមនេះទាញចេញពីស្នាដៃបង្កើតឡើងដោយនិស្សិតបីនាក់ គឺ Sidney Williams, Camille Morales និង Anna Chahuneau មកពី The School for Field Studies, Center for Conservation and Development Studies។

គោលបំណង និងវត្ថុបំណងរបស់ ACCB[1] មាន៖

- ដើម្បីលើកកម្ពស់ការសង្គ្រោះសត្វព្រៃពូជក្នុងស្រុកជាជម្រើស និងដើម្បីផ្តល់ការស្តានីតិសម្បទាគ្រប់គ្រាន់ ព្រមទាំងបរិក្ខារដោះលែងទៅវិញ ព្រមទាំងធានាឱ្យមានការថែទាំតាមបទដ្ឋានទទួលស្គាល់ជាអន្តរជាតិ។
- ដើម្បីផ្តល់បរិក្ខារ និងជំនាញបច្ចេកទេសម្រាប់ការបង្កាត់ពូជអភិរក្សសម្រាប់ពូជសត្វជាជម្រើសដែលកំពុងរងការគំរាម និងដើម្បីផ្តួចផ្តើម និងអនុវត្តកម្មវិធីដាក់ឱ្យមានឡើងវិញ និងស្តាចំនួនសត្វព្រៃឡើងវិញឱ្យបានសមស្រប។
- ដើម្បីបម្រើតួនាទីជាមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលសម្រាប់សហគមន៍ មន្ត្រីផ្នែកសត្វព្រៃ និងភ្ញៀវនានាដែលអញ្ជើញមកមជ្ឈមណ្ឌលនេះ ដើម្បីបង្កើនការយល់ដឹង និងកសាងសមត្ថភាពសម្រាប់ការអភិរក្ស និងការការពារ និងគ្រប់គ្រងបរិស្ថាន និងដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ព្រមជាមួយគ្នានោះក៏ផ្សារភ្ជាប់បញ្ហាបរិស្ថានអន្តរជាតិមកក្នុងបញ្ហាបរិស្ថានក្នុងស្រុក។
- ដើម្បីផ្តួចផ្តើមគំនិត និងចូលរួមក្នុងការអភិរក្សសត្វព្រៃ និងសកម្មភាពស្រាវជ្រាវក្នុងប្រទេសកម្ពុជា រួមទាំងនៅក្នុងសកម្មភាពអភិរក្សនៅក្នុងទីតាំងធម្មជាតិ កិច្ចខិតខំស្តាពូជសត្វឡើងវិញ បញ្ជីសារពើភ័ណ្ឌជីវសាស្ត្រចម្រុះ និងការវាយតម្លៃការប្រើប្រាស់ធនធានធម្មជាតិ ព្រមទាំងដើម្បីផ្តល់ព័ត៌មាន ដើម្បីគាំទ្រដល់អនុសាសន៍ការគ្រប់គ្រងសម្រាប់តំបន់ការពារ។

តំបន់ជុំវិញដែលនៅជាប់ ACCB និងក្នុងប្រទេសកម្ពុជាទាំងមូល កំពុងជួបប្រទះសម្ពាធបរិស្ថានកាន់តែច្រើនឡើង ទាំងសម្ពាធដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់ និងការលួចសត្វព្រៃ។[2] បន្ថែមលើការគំរាមកំហែងពីសកម្មភាពជាលក្ខណៈបុគ្គល ពាណិជ្ជកម្មសត្វចិញ្ចឹម និងឧស្សាហកម្មឈើកាន់តែរីកធំឡើង ផ្តល់លទ្ធផលឱ្យមានការខូចខាតទ្វេគុណលើប្រព័ន្ធអេកូឡូស៊ីធម្មជាតិរបស់ប្រទេសកម្ពុជា។ នៅពេលដែលការបាត់បង់ព្រៃឈើ និងការលួចចាប់សត្វក្លាយជាបញ្ហាកាន់តែច្រើនឡើង ACCB បានទទួលសត្វកាន់តែច្រើន ដើម្បីស្តានីតិសម្បទាជារៀងរាល់ឆ្នាំ។ សត្វភាគច្រើនដែលមកដល់ ACCB ត្រូវបានជួយសង្គ្រោះពីពាណិជ្ជកម្មសត្វព្រៃខុសច្បាប់។ គ្រប់ពេលដែលសមស្រប ACCB ដោះលែងសត្វដែលបានស្តានីតិសម្បទារួចចូលទៅក្នុងប្រព័ន្ធអេកូឡូស៊ីកំណើតរបស់ខ្លួនវិញ។ ហេតុនេះ ជាការចាំបាច់ផងដែរដែលបរិវេណធម្មជាតិជុំវិញ ACCB ត្រូវបានការពារ ហើយការលួចចាប់សត្វត្រូវបានលុបបំបាត់។

បញ្ជីខាងក្រោមរាយឈ្មោះពូជសំខាន់ៗមួយចំនួន ដែលបច្ចុប្បន្នមាននៅ ACCB ព្រមទាំងស្ថានភាព IUCN[3] និង CITES ២០១៧[4] របស់សត្វទាំងនោះ៖

[2] Gaughan, A. E., Binford, M.W., & J. Southworth. 2008. Tourism, forest conversion, and land transformations in the Angkor basin, Cambodia. *Applied Geography* , 29 (2), 212-223

[3] បញ្ជីក្រហមនៃពូជសត្វរបស់ IUCN ឆ្នាំ ២០១៧-២។ http://www.iucnredlist.org/. បើកមើលនៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៧។ និយមន័យនៃស្ថានភាពនេះគឺផ្អែកលើចំណាត់ប្រភេទ និងលក្ខខណ្ឌវិនិច្ឆ័យបញ្ជីក្រហម IUCN

Sunda Pangolin (*Manis Javanica*)៖ **ជិតផុតពូជយ៉ាងធ្ងន់ធ្ងរ** ឧបសម្ព័ន្ធ ១

Northern Slow Loris (*Nycticebus bengalensis* )៖ **ងាយរងគ្រោះ** ឧបសម្ព័ន្ធ ១

Pileated Gibbon (*Hylobates pileatus* )៖ **ជិតផុតពូជ** ឧបសម្ព័ន្ធ ១

Silvered Langur (*Trachypithecus germaini* )៖ **ជិតផុតពូជ** ឧបសម្ព័ន្ធ ២

Leopard cat (*Prionailurus bengalensis*)៖ **មិនសូវបារម្ភ** ឧបសម្ព័ន្ធ ២ (ឧបសម្ព័ន្ធ ១ ប្រទេសថៃ)

Greater Adjutant ( *Leptoptilos dubius* )៖ **ជិតផុតពូជ**

Green Peafowl (*Pavo muticus*)៖ **ជិតផុតពូជ** ឧបសម្ព័ន្ធ ២។

## សំណួរពិភាក្សា៖

ផ្អែកចំនួនពីរនៃច្បាប់បរិស្ថាន មានភាពពាក់ព័ន្ធជាពិសេសចំពោះការងាររបស់ ACCB ពោលគឺការជួញដូរសត្វព្រៃ និងការលួចចាប់សត្វ និងការបំផ្លាញទីជម្រក (ជាពិសេសដោយសារការកាប់ឈើ)។ សូមពិចារណាសំណួរខាងក្រោម៖

១. ផ្អែកលើព័ត៌មានទទួលបានក្នុងអំឡុងពេលទស្សនកិច្ចសិក្សា តើស្ថានភាពពាណិជ្ជកម្មសត្វព្រៃក្នុងប្រទេសកម្ពុជាបច្ចុប្បន្នមានស្ថានភាពបែបណា?

២. តើមានបទបញ្ញត្តជាធរមានអ្វីខ្លះ ដើម្បីគ្រប់គ្រងលើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់? តើមានអ្វីខ្លះដែលអាចធ្វើបាន ដើម្បីកែលម្អការអនុវត្តឱ្យកាន់តែប្រសើរថែមទៀត?

៣. តើអ្វីជាយុទ្ធវិធីផ្លូវច្បាប់ល្អបំផុតដើម្បីរារាំងដល់ពាណិជ្ជកម្មសត្វព្រៃខុសច្បាប់?

---

២០០១។ កំណែទី ៣.១។ **ជិតផុតពូជធ្ងន់ធ្ងរ** (CR)៖ ត្រូវបានចាត់ទុកថា កំពុងប្រឈមហានិភ័យខ្ពស់យ៉ាងខ្លាំងនៃការផុតពូជនៅក្នុងព្រៃធម្មជាតិ **ជិតផុតពូជ** (EN)៖ ត្រូវបានចាត់ទុកថា កំពុងប្រឈមហានិភ័យខ្ពស់ចំពោះការផុតពូជនៅក្នុងព្រៃធម្មជាតិ **ងាយរងគ្រោះ** (VU)៖ ត្រូវបានចាត់ទុកថា កំពុងប្រឈមហានិភ័យខ្ពស់នៃការផុតពូជនៅក្នុងព្រៃធម្មជាតិ។ **មិនសូវបារម្ភ** (LC)៖ មានច្រើនពាសពេញ និងពូជដែលនៅសម្បូរ ត្រូវបានដាក់បញ្ចូលក្នុងចំណាត់ប្រភេទនេះ។

[4] អនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើពូជសត្វព្រៃ និងរុក្ខជាតិជិតផុតពូជ (CITES) ២០១៧។ https://cites.org/eng/app/index.php. បើកមើលថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៧។ "ឧបសម្ព័ន្ធ ១ រាយឈ្មោះពូជដែលជិតផុតពូជបំផុតក្នុងចំណោមសត្វ និងរុក្ខជាតិដែលត្រូវបានរាយឈ្មោះនៅក្នុង CITES។ ពូជទាំងនេះរងការគំរាមកំហែងដោយការផុតពូជ ហើយ CITES ហាមឃាត់ពាណិជ្ជកម្មអន្តរជាតិចំពោះសំណាកពូជទាំងអស់នេះ លើកលែងនៅពេលដែលគោលបំណងនៃការនាំចូលគឺពុំមែនសម្រាប់ពាណិជ្ជកម្ម ឧ. ដូចជាសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រជាដើម... ឧបសម្ព័ន្ធ ២ រាយឈ្មោះពូជដែលឥឡូវនេះពុំរងការគម្រាមកំហែងចំពោះការផុតពូជទេ ប៉ុន្តែអាចក្លាយជាជិតផុតពូជបានបើពាណិជ្ជកម្មពុំគ្រប់គ្រងបានយ៉ាងម៉ត់ចត់ទេនោះ... ពាណិជ្ជកម្មអន្តរជាតិចំពោះពូជក្នុងឧបសម្ព័ន្ធ ២ អាចទទួលបានការអនុញ្ញាតតាមរយៈការប្រគល់លិខិតអនុញ្ញាតនាំចេញ ឬលិខិតអនុញ្ញាតឱ្យនាំចេញឡើងវិញ"។

៤. ACCB ចូលរួមនៅក្នុងកម្មវិធីបង្កាត់ពូជអភិរក្ស*នៅក្រៅទីតាំងធម្មជាតិ* (*ex situ*)។ ACCB បញ្ជាក់ថា "គោលបំណងទូទៅរបស់ការបង្កាត់ពូជអភិរក្ស*នៅក្រៅទីតាំងធម្មជាតិ* គឺដើម្បីផ្តល់តម្លៃបន្ថែមដើម្បីបំពេញបន្ថែមចំពោះវិធានការអភិរក្ស*នៅក្នុងទីតាំងធម្មជាតិ* ពោលគឺតាមរយៈការបង្កើតពូជសត្វដែលត្រូវគេចាប់មកដែលប្រឈមហានិភ័យនៃការផុតពូជនៅក្នុងព្រៃឱ្យមានសុវត្ថិភាព ឬដើម្បីបង្កើតកូនចៅសម្រាប់ការដាក់ឱ្យមានឡើងវិញនាពេលអនាគត និងកម្មវិធីបង្កើតចំនួនសត្វព្រៃឡើងវិញ ដើម្បីជួយដល់ការស្តាឡើងវិញនូវចំនួនសត្វព្រៃដែលបានថយចុះ ឬផុតពូជពីក្នុងមូលដ្ឋាន។"[5]

ផ្អែកលើព័ត៌មានបានទទួលក្នុងអំឡុងទស្សនកិច្ចសិក្សា តើបញ្ហាប្រឈមអ្វីខ្លះដែលរារាំងជោគជ័យនៃកម្មវិធីទាំងអស់នេះ? តើមានវិធានការផ្អែកច្បាប់អ្វីខ្លះដែលអាចដាក់ឱ្យមាន ដើម្បីពង្រឹងការការពារទីតាំងលែងសត្វទៅវិញ ជាពិសេសទាក់ទងជាមួយការកាប់ឈើខុសច្បាប់ និងការបំផ្លាញទីជម្រកសត្វព្រៃ?

[5] មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវសាស្ត្រចម្រុះ ឆ្នាំ ២០១៧។ *ការសង្គ្រោះសត្វព្រៃ និងការបង្កាត់ពូជដើម្បីអភិរក្សពូជសត្វជិតផុតពូជ។* http://www.accb-cambodia.org/en/activities.php. បើកមើលនៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១៧។